00531192

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

A371/2/12

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**គាំទនាំទប្រជាកម្ពុជ្ជ ... (ច្បាប់)**

**ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៦៤) |
| ចំពោះមុខ៖ | ចៅក្រម ប្រាក់ គីមសាន, ប្រធាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម ន៉ី ធុល |
| | ចៅក្រម Catherine MARCHI-UHEL |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ៖ | ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 11 / 06 / 2010
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**សាធារណៈ(ដោយកោសលុប)**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពទីជម្រៅនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ជនត្រូវចោទ**

លោក អៀង សារី

អង្គបុរេជំនុំជម្រះ ECCC * CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៨១៤ ទូរសារ (៨៥៥) ២៣ ២១៩ ៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh, Cambodia, PO Box 71, Tel: (855) 23 219 814 Fax: (855) 23 219 841 Web: www.eccc.gov.kh

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦៤)

លេខ/No. A371/2/12

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

លោក នី ចាន់ឌី

លោក Mahdev MOHAN

កញ្ញា Lima NGUYEN

លោក គីម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Elizabeth-Joelle RABESANRATANA

លោកស្រី Annie DELAHAIE

លោក Philippe CANONNE

លោកស្រី Martine JACQUIN

លោកស្រី Fabienne TRUSSES-NAPROUS

លោកស្រី Françoise GAUTRY

លោកស្រី Isabelle DURAND

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោក Ferdinand DJAMMEN

លោក ឡោ ជុនធី

លោកស្រី ស៊ិន សុវ៉ន

លោក សំ សុគង់

លោក ហុង គីមសួន

លោក គង់ ពិសី

លោក គង់ ហេង

លោកស្រី Silke STUDZINSKY

លោក Olivier BAHOUGNE

លោកស្រី Marie GUIRAUD

លោក Partirck BAUDOUIN

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោក Julien RIVET

លោក Pascal AUBOIN

**<u>សហមេធាវីការពារជនត្រូវចោទ</u>**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**<u>ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីការពារ</u>**

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង*

00531194



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (**"អ.វ.ត.ក"**) បានទទួល"បណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំរបស់ក្រុមមេធាវីការពារក្ដីរបស់គាត់ ដើម្បីថតសំឡេង/រូបភាពវីដេអូ នៃការជួបគ្នានៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក" ដែលសហមេធាវីការពារក្ដីរបស់ជនត្រូវចោទ អៀង សារី ("ជនត្រូវចោទ" និង "ដើមបណ្ដឹងឧទ្ធរណ៍" បានដាក់ជូនកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០ កន្លងទៅនេះ ("បណ្ដឹងឧទ្ធរណ៍")[១] ។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ សហមេធាវីការពារក្ដីរបស់លោក អៀង សារី បានដាក់ "សំណើសុំការអនុញ្ញាតពីមន្ទីរឃុំឃាំង អ.វ.ត.ក ដើម្បីឱ្យមេធាវីការពារក្ដីថតសំឡេង/រូបភាពវីដេអូ ជនត្រូវចោទនៅក្នុងមន្ទីរឃុំឃាំង" (សំណើសុំ)[២]។ សំណើសុំត្រូវបានធ្វើឡើងបន្ទាប់ពីមានការណែនាំរបស់ប្រធានមន្ទីរឃុំឃាំងថា ដីកានោះ គឺជាការចាំបាច់ ហើយត្រូវចេញដោយសហចៅក្រមស៊ើបអង្កេត[៣] ក្រោយពីមេធាវីការពារជនត្រូវចោទបានជូនដំណឹងពីចេតនារបស់ខ្លួនថា នឹងថតសំឡេង/រូបភាពវីដេអូ ក្នុងពេលជួបជាមួយកូនក្ដីរបស់ខ្លួន។ សំណើបញ្ជាក់ថា ថតសំឡេង/រូបភាពវីដេអូគឺជាការចាំបាច់ ដោយយោងតាមតម្រូវការនៃត្រៀមរៀបចំឱ្យបានត្រឹមត្រូវនិងពេញលេញ ដើម្បីការពារជនត្រូវចោទក្នុងដំណាក់កាលមុនអង្គសេចក្ដី និងផ្អែកតាមមាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង)[៤] មាត្រា ៣៥ថ្មី នៃច្បាប់ស្ដីពីការបង្កើត

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

---

[១] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងការបដិសេធរបស់ ក.ស.ច.ស ទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្ដីសុំថតសំឡេង/រូបភាពវីដេអូ នៃការជួបគ្នានៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០ ឯកសារ A371/2/1.1("បណ្ដឹងឧទ្ធរណ៍")

[២] សំណើសុំដីកាបង្គាប់ឱ្យមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក អនុញ្ញាតឱ្យមេធាវីការពារក្ដីថតសំឡេង/រូបភាពវីដេអូកូនក្ដីរបស់យើងខ្ញុំនៅមន្ទីរឃុំឃាំង ចុះថ្ងៃទី១៨ មីនា ឆ្នាំ២០១០ ឯកសារ A371 ("សំណើសុំ") ។

[៣] សំណើសុំ ទំព័រ ១។

[៤] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាស្ដីពីការចោទប្រកាន់បទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ ("កិច្ចព្រមព្រៀង")។

អង្គជំនុំជម្រះវិសាមញ្ញ (ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក)[៥] និងមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ[៦] ដែលធានាសិទ្ធិទទួលបានពេលវេលា និងការត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ការត្រៀមរៀបចំការការពារ[៧]។

២. នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើសុំ ដោយមូលហេតុថា សំណើសុំនោះគ្មានមូលដ្ឋានច្បាប់គាំទ្រ[៨]។ ជាពិសេស សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ១) ទោះបីជាកិច្ចព្រមព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ធានាថាជនដែលរងការចោទប្រកាន់ពីបទអាជ្ញា ត្រូវទទួលបានពេលវេលា និងលក្ខណៈគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំការពារខ្លួនក៏ដោយ ក៏លិខិតុបករណ៍ទាំងនេះមិនបានចែងធានាជាក់លាក់ ឬ មិនជាក់លាក់អំពីសិទ្ធិរបស់មេធាវីការពារក្តីក្នុងការនាំយកឧបករណ៍ថតចូល និងប្រើនៅក្នុងមន្ទីរឃុំឃាំងទេ[៩] និង ២) ពិចារណាលើធនធាន ការត្រៀមលក្ខណៈ និងជំនួយដែលមានបច្ចុប្បន្នសម្រាប់ជនត្រូវចោទ[១០] និងបញ្ជាក់ថា សិទ្ធិជនត្រូវចោទដែលចែងក្នុងលិខិតុបករណ៍ទាំងនេះត្រូវបានគោរពយ៉ាងពេញលេញអស់ហើយ[១១]។

៣. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ សហមេធាវីខ្មែររបស់ជនត្រូវចោទ បានដាក់សេចក្តីជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការងការជំទាស់ ហើយសហមេធាវីទាំងពីរបានដាក់បណ្តឹងឧទ្ធរណ៍

---

[៥] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ រួមទាំងវិសោធនកម្ម ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់បង្កើត អ.វ.ត.ក") ។

[៦] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ 999 UNTS 171 និង 1057 UNTS 407 ("កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ") មាត្រា ១៤(៣)(ខ)។

[៧] សំណើសុំ ទំព័រ ១។

[៨] លិខិតឆ្លើយឆ្លងពីសហចៅក្រមស៊ើបអង្កេត ទៅក្រុមមេធាវីការពារ អៀង សារី (កម្មវត្ថុ: សំណើសុំថតសំឡេង/រូបភាពវីដេអូនៅមន្ទីរឃុំឃាំង ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០ ឯកសារA371/1 ទំព័រ ២ ("ដីកាដែលរងការជំទាស់")។

[៩] ដីកាដែលរងការជំទាស់ ទំព័រ ១។

[១០] ដីកាដែលរងការជំទាស់ លេខយោង ៥ ដែលយោងទៅវក្រវិធាន ៩.១៥-៩.២៤ និងវិធាន ១៤ នៃវិធានគ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះចំពោះមុខ អ.វ.ត.ក។

[១១] ដីកាដែលរងការជំទាស់ ទំព័រ ២។

នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០។ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ដូចតទៅនេះ៖ ១) ប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍តាមវិធាន ២១ និងវិធាន ៧៤(៣)(ច) (វិសោធនកម្មទី៥)[១២] ២) បដិសេធចោលការច្រានចោលសំណើរបស់សហចៅក្រមស៊ើបអង្កេត និង ៣) បង្គាប់ឱ្យមន្ទីរឃុំឃាំងអនុញ្ញាតឱ្យមេធាវីការពារក្តីថតសំឡេង/រូបភាពវីដូអូជនត្រូវចោទ។ ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានស្នើសុំឱ្យបើកសវនាការផ្ទាល់មាត់ជាសាធារណៈ ដោយអះអាងថាបណ្តឹងឧទ្ធរណ៍នេះ ដោះស្រាយការបំពានលើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ ដែលជាសិទ្ធិមូលដ្ឋានរបស់ខ្លួន ហើយវាទំនងជាមានឥទ្ធិពលទៅលើធម្មនុញ្ញភាព និងភាពជឿជាក់លើ អ.វ.ត.ក ហេតុដូច្នេះ បណ្តឹងនេះត្រូវតែដោះស្រាយក្នុងនីតិវិធីដោយចំហ និងមានតម្លាភាព[១៣]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានបន្ថែមថាបណ្តឹងនេះត្រូវបានធ្វើឡើងជាសម្ងាត់ ដោយសារខ្លួនយល់ថាវាពាក់ព័ន្ធតែបែបបទរដ្ឋបាលធម្មតា ហើយបណ្តឹងឧទ្ធរណ៍នេះមិនពិភាក្សាបញ្ហាសម្ងាត់នោះទេ[១៤]។

៤. នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ការិយាល័យសហព្រះរាជអាជ្ញាបានដាក់សារណាតប[១៥] ដែលក្នុងសារណានោះ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួនគាំទ្របណ្តឹងឧទ្ធរណ៍នេះ ប៉ុន្តែបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលសំណើសុំបើកសវនាការផ្ទាល់មាត់ជាសាធារណៈ ដោយសារគ្មានការតវ៉ាលើកម្មវត្ថុចម្បងនៃបណ្តឹងឧទ្ធរណ៍នេះទេ[១៦]។

៥. នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញដីកាកំណត់សវនាការដែលក្នុងនោះអង្គបុរេជំនុំជម្រះបានសម្រេចថាត្រូវធ្វើសវនាការ *ជាអសាធារណៈ* ដោយអនុលោមតាមវិធាន ៧៧(៥) នៃវិធានផ្ទៃក្នុង ហើយបានបញ្ជាក់ថា សវនាការនឹងពិភាក្សាតាមមូលដ្ឋាន នៃសារណាបណ្តឹងឧទ្ធរណ៍ ដែលត្រូវបានធ្វើឡើងអនុលោមតាមវិធាន ៧៥(៣) និងសារណាតបរបស់

---

[១២] វិធានផ្ទៃក្នុង វិសោធនកម្មទី៥ ដែលបានធ្វើឡើងនៅថ្ងៃទី៩ ខែកុម្ភៈ ២០១០។

[១៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧។

[១៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨។

[១៥] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពី សំណើសុំថតសំឡេង/រូបភាពវីដេអូនៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ឯកសារA371/2/2 (“សេចក្តីសង្កេត”)។

[១៦] សារណាតប កថាខណ្ឌ ៥-៦។

សហព្រះរាជអាជ្ញា នឹងត្រូវចាត់ទុកថាបានអាន ដោយអង្គបុរេជំនុំជម្រះ នៅពេលអង្គបុរេជំនុំជម្រះ បានស្ដាប់ចម្លើយតបផ្ទាល់មាត់ក្នុងសវនាការ។

៦. តាមលិខិតដែលផ្ញើជូនប្រធានមន្ទីរឃុំឃាំង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះ បានស្នើសុំការបំភ្លឺពាក់ព័ន្ធនឹងវិធាន និងការអនុវត្តស្ដីពីការអនុញ្ញាតឱ្យមនុស្ស និងយកឧបករណ៍ ចូលក្នុងមន្ទីរឃុំឃាំង[១៧]។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ប្រធានមន្ទីរឃុំឃាំងបានដាក់លិខិត មួយជូនអង្គបុរេជំនុំជម្រះ ("សេចក្ដីបំភ្លឺ")[១៨] ដោយមានភ្ជាប់មកជាមួយនូវសេចក្ដីជូនដំណឹងលេខ ០០៧/០៨ ម.ឃ.ស.ក ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០៨ ("សេចក្ដីជូនដំណឹង")។ សេចក្ដីបំភ្លឺ និង សេចក្ដីជូនដំណឹងដែលភ្ជាប់មកជាមួយនោះ បានចែងពីបញ្ជីដែលមិនបានរាយមុខវត្ថុដែលបាន អនុញ្ញាត និងហាមឃាត់ទាំងអស់ទេ[១៩]។ តាមលិខិតចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំ ជម្រះបានអញ្ជើញប្រធានមន្ទីរឃុំឃាំងឱ្យចូលរួមសវនាការ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០[២០]។

៧. នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានបើកសវនាការ *ជាអសាធារណៈ* ដោយ អនុលោមតាមវិធាន ៧៧(៥)។ ក្រៅពីធ្វើសវនាការលើចម្លើយតបរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ [redacted] ប្រធានមន្ទីរឃុំឃាំងបានបង្ហាញខ្លួន ក្នុងសវនាការតាមការអញ្ជើញរបស់ អង្គបុរេជំនុំជម្រះ ព្រមទាំងបានឆ្លើយតបនឹងសំណួររបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ និងអង្គបុរេជំនុំជម្រះ ផងដែរ[២១]។

៨. អង្គបុរេជំនុំជម្រះយល់ឃើញថា ការបើកលទ្ធភាពឱ្យសាធារណៈជនអាចបើកមើលសារណានានា និងការដាក់សាលដីកានេះជាឯកសារសាធារណៈ អាចឆ្លើយតបគ្រប់គ្រាន់ទៅនឹងការព្រួយបារម្ភ របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ពីលក្ខខណ្ឌតម្លាភាព និងការផ្សព្វផ្សាយជាសាធារណៈបាន។

---

[១៧] លិខិតរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ស្ដីពីបទប្បញ្ញត្តិ និងការអនុវត្តរបស់មន្ទីរឃុំឃាំង ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១០ ឯកសារA371/2/8។

[១៨] សេចក្ដីបំភ្លឺ ស្ដីពីបទប្បញ្ញត្តិ និងការអនុវត្តរបស់មន្ទីរឃុំឃាំង ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ A371/2/10 ("សេចក្ដីបំភ្លឺ")។

[១៩] សេចក្ដីបំភ្លឺ ទំព័រ ១ និងសេចក្ដីជូនដំណឹង ទំព័រ ១។

[២០] លិខិតអញ្ជើញ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ឯកសារ A371/2/11។

[២១] ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នា២០១០ ទំព័រ១៤ (បន្ទាត់ ១) ដល់ ទំព័រ២៣ (បន្ទាត់១៣)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

00531198

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦៤)

លេខ/No. A371/2/12

## II. ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

៩. ដីកាដែលរងការជំទាស់ត្រូវបានចេញនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ និងត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០។ សហមេធាវីខ្មែររបស់ជនត្រូវចោទបានដាក់សេចក្ដីជូនដំណឹងពីការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលរងការជំទាស់នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០។ បណ្ដឹងឧទ្ធរណ៍ត្រូវបានធ្វើឡើង នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០ ដូច្នេះបណ្ដឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេលដូចបានកំណត់ក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

១០. បណ្ដឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងអនុលោមទៅតាមវិធាន ៧៤(៣)(ច), ២១(១) និងវិធាន ២១(២) នៃវិធានផ្ទៃក្នុង។ វិធាន ៧៤(៣)(ច) ចែងថា:

"វិធាន ៧៤. មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ

៣. ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម៖

[...]

ច- ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ"[២២]។

១១. អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហាថាតើឧបករណ៍ ឬវត្ថុដែលសមាជិកក្រុមមេធាវីការពារក្ដីអាចឬមិនអាចយកចូល-ចេញ និងប្រើក្នុងមន្ទីរឃុំឃាំង ក្នុងពេលជួបជាមួយកូនក្ដីរបស់ខ្លួនក្នុងពេលឃុំខ្លួនបណ្ដោះអាសន្ននោះ បង្កើតបានជាផ្នែកមួយ នៃទម្រង់ឃុំខ្លួនជនត្រូវចោទដែរឬទេ។ ដូច្នេះ ទិដ្ឋភាពណាមួយនៃទម្រង់ឃុំខ្លួនបណ្ដោះអាសន្ន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពរបស់អាជ្ញាធរមានសមត្ថកិច្ច ខាងតុលាការរបស់ អ.វ.ត.ក និងមានកំរិតជាក់លាក់ត្រឹមតែតម្រូវការនៃដំណើរការនីតិវិធីប៉ុណ្ណោះ[២៣]។ ក្នុងវិសាលភាពដែលខ្លួនត្រូវសម្រេចលើទិដ្ឋភាព

---

[២២] វិធាន ៧៤(៣)(ច) និងវិធានផ្ទៃក្នុង វិសោធនកម្មទី៥ ដែលបានធ្វើឡើងនៅថ្ងៃទី៩ ខែកុម្ភៈ ២០១០។

[២៣] ចូរអានវិធាន ២១ នៃវិធានផ្ទៃក្នុង។ ចូរអានផងដែរ "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទជាមួយនឹងប្រពន្ធរបស់គាត់" ចុះថ្ងៃទី៣០ ខែមេសា ឆ្នា២០០៨ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ០៥) *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត[illegible] អនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង*

ជាក់លាក់នៃការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ននោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាដែលរងការជំទាស់ បង្កើតបានជាដីកា "ដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន" តាមស្មារតីនៃវិធាន ៧៤(៣)(ច) នៃវិធានផ្ទៃក្នុង ហេតុដូច្នេះ ជនត្រូវអាចប្តឹងឧទ្ធរណ៍បាន។

១២. ដូចបានកត់សំគាល់ខាងលើ ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានលើកឡើងដែរថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមវិធាន ២១។ ក្នុងករណីនេះ ផ្នែកដែលពាក់ព័ន្ធនៃវិធាន ២១ ចែងថា ៖

"វិធាន ២១. គោលការណ៍ជាសារវ័ន្ត

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក- ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ [...]

២. វិធានការចាប់បង្ខំទាំងឡាយណាចំពោះបុគ្គលណាម្នាក់ត្រូវធ្វើឡើងដោយ ឬស្ថិតនៅក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់ ពីអាជ្ញាធរមានសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ។ វិធានការនេះត្រូវតែកម្រិតតឹងរ៉ឹងបំផុត សម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី ដោយសមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និងដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឲ្យបានពេញលេញ"[២៤]។

---

ERN00184951-00184956, A104/II/7 កថាខណ្ឌ ១៥ និង ១៧ នៃ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការប្រាស្រ័យទាក់ទងគ្នា")។

[២៤] វិធាន ២១ នៃវិធានផ្ទៃក្នុង វិសោធនកម្មទី៥ ដែលបានធ្វើឡើងនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០។ បន្ថែមលើវិធាន ២១(២) បណ្តឹងឧទ្ធរណ៍បានយោងទៅរកគោលការណ៍ទី ៩ នៃគោលការណ៍ស្តីពីការការពារជនគ្រប់រូបទល់នឹងគ្រប់រូបភាពនៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ ដែលមហាសន្និបាត អ.ស.ប បានអនុម័តក្នុងសេចក្តីសម្រេចសម្ចហភាព ឆ្នាំ១៩៨៨។ អនុលោមតាមគោលណ៍ទី៩ "អាជ្ញាធរដែលចាប់ខ្លួន ឃុំខ្លួនជនណាម្នាក់ ឬស៊ើបអង្កេតរឿងក្តីណាមួយ ត្រូវអនុវត្តតែអំណាចទាំងឡាយដែលច្បាប់ផ្តល់ឲ្យ ហើយការអនុវត្តអំណាចនេះនឹងត្រូវបើកឲ្យមានការតវ៉ាទៅអំណាច ឬអាជ្ញាធរតុលាការ, បណ្តឹងឧទ្ធរណ៍កថាខណ្ឌទ១៤។

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់[illegible]សម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅ[illegible]*

00531200



១៣. ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងថាដីកាដែលរងការជំទាស់ បំពានលើវិធាន២១ ដោយសារដីកានេះ មិនបាន "ការពារសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការត្រៀមលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារ និងទំនាក់ទំនងជាមួយមេធាវី និងដោយសារដីកានេះជាវិធានការបង្ខំ ដែលមិនកំរិតតឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃដំណើរការនីតិវិធីនោះទេ"[២៥]។ អង្គបុរេជំនុំជម្រះត្រូវពិនិត្យថា តើវិធាន២១ តម្រូវ ឬក៏មិនតម្រូវឲ្យខ្លួនប្រកាន់យកការបកស្រាយទូលាយអំពីសិទ្ធិរបស់ជនត្រូវចោទ ក្នុងការប្តឹងឧទ្ធរណ៍ដើម្បីធានាឲ្យដំណើរការនីតិវិធីមានយុត្តិធម៌។

១៤. វិធាន២១ ចែងការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ។ ពីដំបូងម្ចាស់បណ្តឹងឧទ្ធរណ៍ បានដាក់សំណើបែបនេះជូនសហចៅក្រមស៊ើបអង្កេត ហើយក្នុងពេលនេះខ្លួនបានដាក់សំណើនេះមកអង្គបុរេជំនុំជម្រះ សុំឲ្យអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចបានរៀបរាប់ក្នុងខលិតុបករណ៍ខាងក្រោម។

១៥. មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងចែងថា៖

> សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះ ជាពិសេស រួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោស រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង និងសិទ្ធិមានពេលវេលា និង[លក្ខណៈ]គ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន និងសិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទ គ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក[២៦]។

១៦. មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖

> នៅក្នុងការចោទប្រកាន់មកលើខ្លួន
> ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា

---

[២៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦។

[២៦] កិច្ចព្រមព្រៀង មាត្រា ១៣។

និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[...]

ខ. ពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសរើសដោយខ្លួនឯង[២៧]

១៧. មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធនយោបាយ ចែងថា៖

ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នា យ៉ាងពេញលេញដូចខាងក្រោម ៖

[...]

ខ. ត្រូវមានពេលវេលា និង[លក្ខណៈ]គ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និង [ប្រាស្រ័យទាក់ទង] ជាមួយមេធាវី ដែលជ្រើសរើសដោយខ្លួនឯង[២៨]។

១៨. ក្រោយពីបានពិចារណាលើសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយអនុលោមតាមមាត្រា ១៣ នៃកិច្ចព្រមព្រៀង មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១ តម្រូវឱ្យខ្លួនបកស្រាយវិធានផ្ទៃក្នុង តាមមធ្យោបាយដែលមានន័យថាបណ្តឹងឧទ្ធរណ៍នេះក៏អាចទទួលយកបានតាមមូលដ្ឋាននៃវិធាន ២១ ផងដែរ។

១៩. នៅទីបញ្ចប់ វិធាន ១ នៃវិធានគ្រប់គ្រងការឃុំខ្លួនជន ដែលរង់ចាំការជំនុំជម្រះ ឬក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍ ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងថា "ការអនុវត្តវិធានទាំងនេះចំពោះករណីនីមួយៗ អាចខុសគ្នាទៅតាមដីកាសម្រេចរបស់សហចៅក្រមនៃ អ.វ.ត.ក ឬ អង្គជំនុំជម្រះនៃ អ.វ.ត.ក"[២៩]។ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះក៏អាចទទួលយកបានដោយផ្អែកលើវិធាននេះដែរ។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

---

[២៧] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥។

[២៨] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា ១៤។

[២៩] វិធានគ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះចំពោះមុខ អ.វ.ត.ក ("វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង")។

២០. បន្ទាប់មក អង្គបុរេជំនុំជម្រះបានពិនិត្យមើលអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។

## III. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

២១. ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងនូវមូលដ្ឋានសំខាន់ៗបីនៃបណ្តឹងឧទ្ធរណ៍ ដោយអះអាងថា ដីកាដែលរងការជំទាស់នេះ៖ ១) បំពានលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[៣០] ២) ដីកានេះគ្មានសុពលភាពទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតមិនមានអំណាចបដិសេធសំណើនេះទេ[៣១] និង ៣) ដីកានេះគ្មានសំអាងហេតុ[៣២]។

២២. អង្គបុរេជំនុំជម្រះបានយោងទៅរកស្តង់ដារសម្រាប់ការពិនិត្យដូចខាងក្រោម ដែលអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍នានាដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ[៣៣]។ សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត អាចត្រូវបានបដិសេធចោលតែក្នុងករណីដែល ម្ចាស់បណ្តឹងឧទ្ធរណ៍អាចបង្ហាញថា សេចក្តីសម្រេចដែលរងការតវ៉ានោះ ១) បានផ្អែកលើការបក-ស្រាយច្បាប់ជាធរមានមិនត្រឹមត្រូវ, ២) ផ្អែកលើសេចក្តីដ្ឋានអង្គហេតុខុសពីការជាក់ស្តែង ឬ ៣) មានភាពអយុត្តិធម៌ ឬ មិនសមហេតុផលខ្លាំង ដែលបង្កើតបានជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[៣៤]។ អង្គបុរេជំនុំជម្រះសូមបំភ្លឺថា មិនមែនគ្រប់កំហុសឆ្គងអង្គច្បាប់ ឬ អង្គហេតុ នឹងនាំឱ្យការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតគ្មានសុពលភាព ហើយនាំឱ្យមានការបដិសេធដីកា គ្រប់តែករណីនោះឡើយ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញ

---

[៣០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៨-២៥។

[៣១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៦-២៩។

[៣២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០-៣៥។

[៣៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកតស៊ូតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី១៨ ខែវិច្ឆកា ឆ្នាំ២០០៩ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ២៤) ERN 00402746-00402762, D164/4/13 ("សាលដីកាស្តីពីឃ្លាំងផ្ទុកឯកសាររួម") កថាខណ្ឌ ២៥-២៦។

[៣៤] សាលដីកាស្តីពីឃ្លាំងផ្ទុកឯកសាររួម កថាខណ្ឌ ២៥-២៦។

ថា ១) កំហុសឆ្គងអង្គច្បាប់នាំឱ្យសេចក្ដីសម្រេចគ្មានសុពលភាព, ២) កំហុសឆ្គងអង្គហេតុនាំឱ្យមានភាពអយុត្តិធម៌ ឬ ៣) សេចក្ដីសម្រេច ឬដីកាមិនសមហេតុផលខ្លាំងដែលនាំឱ្យមានសេចក្ដីសន្និដ្ឋានថាសហចៅក្រមស៊ើបអង្កេត មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ។

២៣. មុននឹងពិភាក្សាមូលហេតុទីមួយនៃបណ្ដឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះសូមរំលឹកថា សេចក្ដីជូនដំណឹងបានបញ្ជាក់ថា វត្ថុដែលមិនត្រូវបានអនុញ្ញាតឱ្យយកចូលមន្ទីរឃុំឃាំង[៣៥] រួមមានម៉ាស៊ីនថតរូប និងឧបករណ៍ថតវីដេអូ។ អង្គបុរេជំនុំជម្រះក៏រំលឹកផងដែរថា សក្ខីកម្មរបស់ប្រធានមន្ទីរឃុំឃាំងបានបញ្ជាក់ថា បញ្ជីរាយមុខវត្ថុដែលត្រូវបានអនុញ្ញាត និងហាមឃាត់ ក្នុងសេចក្ដីជូនដំណឹងមិនមែនជាបញ្ជីរាយមុខវត្ថុទាំងអស់នោះទេ ហេតុនោះហើយទើបមន្ទីរឃុំឃាំងមានឆន្ទានុសិទ្ធិ និងតាមពិតបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយហាមមិនឱ្យយកឧបករណ៍ថតសំឡេងចូល[៣៦]។ នៅទីបញ្ចប់ អង្គបុរេជំនុំជម្រះកត់សំគាល់ថា ប្រធានមន្ទីរឃុំឃាំងបានបញ្ជាក់ក្នុងពេលធ្វើសក្ខីកម្មថា ចំពោះការវាយតម្លៃវត្ថុដែលអាចយកចូលមន្ទីរឃុំឃាំងបាន[៣៧] ជាទូទៅ មន្ទីរឃុំឃាំងមិនបានបែងចែកការចូលជួបរបស់មេធាវីការពារ និងភ្ញៀវធម្មតាទេ។ អង្គបុរេជំនុំជម្រះកត់សំគាល់ថា ប្រធានមន្ទីរឃុំឃាំងបានបញ្ជាក់ជាលាយលក្ខណ៍អក្សរថា ទោះបីជាវិធានរបស់មន្ទីរឃុំឃាំង មិនបានអនុញ្ញាតឱ្យយកកុំព្យូទ័រយួរដៃចូលក្ដី ក្នុងការអនុវត្តជាក់ស្ដែងមន្ទីរឃុំឃាំងបានអនុញ្ញាតឱ្យមេធាវីយកកុំព្យូទ័រយួរដៃចូល នៅពេលមេធាវីជួបជាមួយកូនក្ដី[៣៨]។

២៤. ឥឡូវនេះ អង្គបុរេជំនុំជម្រះពិភាក្សាមូលហេតុទីមួយនៃបណ្ដឹងឧទ្ធរណ៍។

**ក. តើដីកាដែលរងការជំទាស់បំពានលើសិទ្ធិជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែរឬទេ?**

២៥. ចំពោះមូលហេតុទីមួយនៃបណ្ដឹងឧទ្ធរណ៍ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានអះអាងថា ដីកាដែលរងការជំទាស់បំពានលើសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ក្នុងការត្រៀមលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន

---

[៣៥] សេចក្ដីជូនដំណឹង ទំព័រ ១។

[៣៦] ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ទំព័រ១៨ (បន្ទាត់ ៦-១២)។

[៣៧] ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ទំព័រ២២ (បន្ទាត់ ៥-១៣)។

[៣៨] សេចក្ដីបំភ្លឺ ទំព័រ ១។

និងទំនាក់ទំនងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស ដែលត្រូវបានធានាដោយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ១៣ នៃកិច្ចព្រមព្រៀង មាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក និងមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ[៣៩]។ ក្រៅពីការបំពានលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទាក់ទងជាមួយមេធាវី និងសិទ្ធិទទួលបានការត្រៀមលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារក្តី សហមេធាវីខ្មែររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍បានបញ្ជាក់ក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ត្រូវបានបំពានកាន់តែធ្ងន់ធ្ងរ ដោយសារដីកាដែលរងការជំទាស់នេះបំពានលើសិទ្ធិជនត្រូវចោទក្នុងការជួយដល់មេធាវីការពាររបស់ខ្លួន[៤០]។

២៦. ក្នុងសារណាតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងថាដីកាដែលរងការជំទាស់ បានបំពានលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ដែលបានធានាដោយលិខិតុបករណ៍ច្បាប់ដែលយោងខាងលើ[៤១]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាមិនជំទាស់នឹងបណ្តឹងឧទ្ធរណ៍នេះទេ[៤២]។

២៧. វាប្រាកដណាស់ថា មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានចែងថា ជនដែលរងការចោទប្រកាន់ ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួនមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយរួមទាំងសិទ្ធិទទួលបានពេលវេលា និងលក្ខណៈគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងប្រាស្រ័យទាក់ទងជាមួយមេធាវី ដែលជ្រើសរើសដោយខ្លួនឯង។ អានុភាពអនុវត្តរបស់មាត្រា ១៣ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក បានផ្តល់ការណែនាំជាក់លាក់ឱ្យអង្គបុរេជំនុំជម្រះពិចារណា មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ក្នុងករណីនេះ ដោយមិនគិតពីវិធាន ២១ នៃវិធានផ្ទៃក្នុង

---

[៣៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៨-២៥។

[៤០] ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ទំព័រ៩ (បន្ទាត់ ១៥-១៨)។

[៤១] សារណាតប កថាខណ្ឌ ១-៣។

[៤២] ការគាំទ្ររបស់ការិយាល័យសហព្រះរាជអាជ្ញា ត្រូវបានបញ្ជាក់ក្នុងសវនាការផ្ទាល់មាត់ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០។ ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ទំព័រ២៣ (បន្ទាត់ ១៨-២៥)។

00531205



អង្គបុរេជំនុំជម្រះត្រូវតែពិនិត្យថាតើដីកាដែលរងការជំទាស់នេះ បានបំពាន ឬមិនបានបំពានលើសិទ្ធិទាំងឡាយរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលបានការពារដោយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែរឬទេ។

២៨. នៅក្នុងសំណើសុំនេះ មេធាវីការពារក្តីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាបង្គាប់អនុញ្ញាតឱ្យមានការថតសំឡេង/រូបភាពវីដេអូ នៃការជួបគ្នារវាងជនត្រូវចោទ និងក្រុមមេធាវីការពារក្តី "ដោយសារតែតម្រូវការក្នុងការត្រៀមរៀបចំកិច្ចការពារក្តីរបស់ [ជនត្រូវចោទ] នៅដំណាក់កាលមុនការជំនុំជម្រះ ឱ្យបានត្រឹមត្រូវពេញលេញ"[៤៣]។ មេធាវីការពារក្តីរៀបរាប់ថា ការថតសំឡេង/រូបភាពវីដេអូ អំពីកិច្ចប្រជុំជាមួយកូនក្តី គឺជាផ្នែកមួយ "ដ៏សំខាន់[៤៤]" និង "ចាំបាច់[៤៥]" នៃកិច្ចត្រៀមរៀបចំការការពារក្តីឱ្យជនត្រូវចោទ។ មេធាវីការពារក្តី បានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតថា ការថតសំឡេង/រូបភាពវីដេអូនេះ នឹងត្រូវយកមកប្រើប្រាស់"សម្រាប់តែគោលបំណង" រៀបចំការការពារក្តីររបស់ជនត្រូវចោទ នៅដំណាក់កាលមុនការជំនុំជម្រះតែប៉ុណ្ណោះ[៤៦]។ ក្នុងសារណារបស់ខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ មេធាវីអន្តរជាតិរបស់ដើមបណ្តឹងឧទ្ធរណ៍បានជម្រាបជូនតុលាការថា ការថតសំឡេង/រូបភាពវីដេអូ គឺជាការចាំបាច់ ដើម្បីឱ្យជនត្រូវចោទប្រាស្រ័យទាក់ទងជាមួយមេធាវី ដែលគាត់បានជ្រើសរើសដោយខ្លួនឯង[៤៧]។ ថ្វីបើចម្លើយរបស់ប្រធានមន្ទីរឃុំឃាំង ដែលហាក់បីដូចជាចង់លើកឡើងថា វាជាភារកិច្ចរបស់ក្រុមមេធាវីការពារក្តីក្នុងការរៀបចំកិច្ចការពារនៅក្នុងរង្វង់ច្បាប់ជាធរមាន និងការអនុវត្តនៅមន្ទីរឃុំឃាំងក្តី[៤៨] ក៏ជនត្រូវចោទមានសិទ្ធិប្រាស្រ័យទាក់ទងជាមួយមេធាវីការពារក្តីដែលខ្លួនជ្រើសរើសដោយខ្លួនឯង។

២៩. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ១ នៃវិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង មានវិសាលភាព

---

[៤៣] សំណើសុំ ទំព័រ ១។

[៤៤] សំណើសុំ ទំព័រ ១ ។

[៤៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២២ ។

[៤៦] សំណើសុំ ទំព័រ ២ ។

[៤៧] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ត្រង់ទំព័រទី ១២ (បន្ទាត់ទី ២៣) ដល់ទំព័រទី ១៣ (បន្ទាត់ទី ១១)។

[៤៨] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ត្រង់ទំព័រទី ១៨ (បន្ទាត់ទី ២២) ដល់ទំព័រទី ១៩ (បន្ទាត់ទី ៣)។

ទូលំទូលាយគ្រប់គ្រាន់ ក្នុងការអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាទៅលើសំណើសុំ។ វិធាន ១ នៃវិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំងប្រមើលឃើញជាមុនថា បញ្ហាទាក់ទងទៅនឹងការឃុំឃាំងអាចខុសគ្នាទៅតាមរឿងក្តីនីមួយៗ និងបានចែងយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតគឺជាស្ថាប័នមួយដែលសមស្របក្នុងការធ្វើការសម្រេចសេចក្តីបែបនេះ។

៣០. នៅក្នុងដីកាដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា ក្នុងការអះអាងគាំទ្រដល់សំណូមពរដែលបានស្នើសុំ មេធាវីការពារក្តីបានយោងទៅលើការធានាដែលមានចែងក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[៤៩]។ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើសុំនេះ ដោយយោងទៅលើមូលដ្ឋានដែលថា "លិខិតុបករណ៍ច្បាប់ទាំងនេះពុំ..បានធានាឱ្យបានជាក់លាក់ ឬមិនជាក់លាក់ នូវសិទ្ធិរបស់ក្រុមមេធាវីការពារក្តីក្នុងការនាំយកឧបករណ៍ថតសំឡេង/រូបភាពវីដេអូ ចូលទៅក្នុងមន្ទីរឃុំឃាំង និងប្រើប្រាស់ដើម្បីបំពេញកិច្ចរៀបចំការពារក្តីនោះទេ"[៥០]។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា យោងតាមកិច្ចព្រមព្រៀង ច្បាប់បង្កើត អ.វ.ត.ក និង កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ សិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ "កំពុងទទួលបានការគោរពយ៉ាងពេញលេញរួចស្រេចទៅហើយ" ហើយសហចៅក្រមស៊ើបអង្កេតមិនឃើញមានមូលដ្ឋានគតិយុត្តិណាមួយ ដើម្បីចេញដីកាអនុញ្ញាតឱ្យនាំយកឧបករណ៍ទាំងនេះចូលក្នុងមន្ទីរឃុំឃាំងនោះឡើយ[៥១]។

៣១. សហចៅក្រមស៊ើបអង្កេត គឺពិតជាត្រឹមត្រូវនៅត្រង់ថា បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់បង្កើត អ.វ.ត.ក និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលបានលើកឡើង មិនបានអនុញ្ញាតឱ្យបានច្បាស់លាស់ចំពោះការប្រើប្រាស់ឧបករណ៍ថតសំឡេង/រូបភាពវីដេអូ ដោយក្រុមមេធាវីការពារក្តីនៅក្នុងមន្ទីរឃុំឃាំងនោះឡើយ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការមិនមានការអនុញ្ញាតឱ្យបានច្បាស់លាស់ ក្នុងការផ្តល់សិទ្ធិឱ្យប្រើប្រាស់ប្រភេទឧបករណ៍ជាក់លាក់ប្រភេទនេះ

[៤៩] ដីកាដែលរងការជំទាស់ ទំព័រទី ១ ។

[៥០] ដីកាដែលរងការជំទាស់ ទំព័រទី ១ ។

[៥១] ដីកាដែលរងការជំទាស់ ទំព័រទី ២ ។

មិនមែនមានន័យថា វាស្ថិតនៅក្រៅវិសាលភាពនៃសកម្មភាព ដែលបានអនុញ្ញាតមិនច្បាស់លាស់ដោយកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយនោះទេ។ ការបកស្រាយអំពីសិទ្ធិរបស់ជនជាប់ចោទចង្អៀតបែបនេះ គឺមិនស្របនឹងកម្មវត្ថុ និងគោលបំណងនៃការធានាឱ្យមានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នោះឡើយ[៥២]។

៣២. ទម្ងន់ពាក្យពេចន៍ក្នុងមាត្រា ៦(៣)(ខ) នៃកតិកាសញ្ញាស្តីពីការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ("the ECHR") ដែលមានលក្ខណៈស្រដៀងគ្នាមែនទែនទៅនឹងមាត្រា ១៤(៣)(ខ) នៃ ICCPR គឺជាកម្មវត្ថុនៃការបកស្រាយតាមផ្លូវតុលាការ[៥៣]។ ការធានាឱ្យមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់នៅក្នុងមាត្រា ៦(៣)(ខ) ត្រូវបានចែងនៅក្នុងបរិបទជាក់លាក់សម្រាប់ការត្រៀមរៀបចំកិច្ចការពារខ្លួន ដូចគ្នានឹងករណីដែលស្ថិតនៅក្រោម ICCPR ដូច្នោះដែរ។ នៅក្នុងរឿងក្តីរវាង *Galystan* *តទល់នឹង ប្រទេសអារមេនី* អង្គជំនុំជម្រះនៃតុលាការសិទ្ធិមនុស្សអឺរ៉ុបសម្រេចថា សិទ្ធិដែលត្រូវបានធានានៅក្រោមមាត្រា ៦(៣)(ខ) នៃ ECHR បង្កប់ន័យថា "សកម្មភាពការពារខ្លួនជាដុំកំភួន...អាចរួមមានអ្វីៗទាំងអស់ ដែលចាំបាច់ដើម្បីត្រៀមរៀបចំកិច្ចការពារខ្លួននៅក្នុងសវនាការលើអង្គសេចក្តី"[៥៤]។ សិទ្ធិនេះត្រូវបានផ្តល់ឱ្យមេធាវីការពារក្តីដើម្បីធានាថា

---

[៥២] នៅក្នុងរឿងក្តីមួយដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានលើកឡើងថា បើទោះជាមានការអនុវត្តជាផ្លូវការ ឬជាបច្ចេកទេសដោយរដ្ឋមួយចំពោះសិទ្ធិរបស់ជនជាប់ចោទក្តី "ក៏ត្រូវតែចងចាំថា [កតិកាសញ្ញាស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន] គឺមិនមែនមានគោលបំណងធានាចំពោះបណ្តាសិទ្ធិទាំងឡាយតាមទ្រឹស្តី ឬតាមការពន្យល់នោះទេ ប៉ុន្តែ គឺធានាចំពោះសិទ្ធិទាំងឡាយតាមការអនុវត្តជាក់ស្តែង និងដែលមានប្រសិទ្ធភាព"។ រឿងក្តីរវាង *Galystan* *តទល់នឹង ប្រទេសអារមេនី* បណ្តឹងឧទ្ធរណ៍លេខ ២៦៩៨៦/០៣ នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលដីកា" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ៨១។

[៥៣] មាត្រា ៦(៣)(ខ) ចែងថា "ជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ ត្រូវមានសិទ្ធិជាអប្បរមាដូចខាងក្រោម៖ (ខ) មានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំកិច្ចការពារខ្លួន"។ កតិកាសញ្ញាស្តីពីការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ ETS No. 005 (ដូចដែលបានធ្វើវិសោធនកម្មរួច), ("the ECHR") មាត្រា ៦(៣)(ខ)។

[៥៤] រឿងក្តីរវាង *Galystan* *តទល់នឹង ប្រទេសអារមេនី* បណ្តឹងឧទ្ធរណ៍លេខ ២៦៩៨៦/០៣ នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលដីកា" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ៨៤។

ជនជាប់ចោទមានឱកាសរៀបចំ "នៅក្នុងមធ្យោបាយមួយសមស្រប" និងចាត់ចែងឱ្យបានទូលំទូលាយពេញលេញនូវទឡ្ហីករណ៍ទាំងអស់ ដែលអាចលើកឡើងនៅក្នុងសវនាការ "ដោយមិនមានការហាមឃាត់អ្វីឡើយ"[៥៥]។ សិទ្ធិនេះ គឺជាបច្ច័យដែលជៀសមិនរួច ហើយគោលបំណងចំបងរបស់សិទ្ធិនេះ គឺបញ្ហាថាតើសំណើសុំ ដូចជាសំណើសុំនេះ ចាំបាច់សម្រាប់ការត្រៀមរៀបចំឱ្យបានគ្រប់គ្រាន់ឬយ៉ាងណានោះ ត្រូវវាយតម្លៃដោយឈរលើមូលដ្ឋាននៃរឿងក្តីនីមួយៗ ដោយយោងតាមកាលៈទេសៈនានា។ ការវិនិច្ឆ័យអំពីភាពគ្រប់គ្រាន់ និងភាពចាំបាច់ តម្រូវឱ្យមានការវាយតម្លៃ និងមិនមែនគ្រាន់តែសំអាងលើការដែលថា ការត្រៀមលក្ខណៈ ឬពេលវេលាជាក់លាក់មួយចំនួនត្រូវបានផ្តល់ជូនហើយនោះទេ។

៣៣. ក្នុងករណីនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា មានកត្តាមួយចំនួនពាក់ព័ន្ធតែចំពោះដំណើរការនីតិវិធីមុនការជំនុំជម្រះក្តីលើជនត្រូវចោទ ដែលត្រូវបានវាយតម្លៃដោយការសម្រេច ថាតើការប្រើប្រាស់ឧបករណ៍ថតសំឡេង/រូបភាពវីដេអូ ស្ថិតនៅក្នុងវង្វង់សិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ដែរឬយ៉ាងណានោះ។ មេធាវីការពារក្តីលើកឡើងយ៉ាងត្រឹមត្រូវថា ខ្លួនមិនចាំបាច់ត្រូវការដាក់ជូនសំណើសុំនេះទៅសហចៅក្រមស៊ើបអង្កេតទេ ប្រសិនបើជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ននោះ[៥៦]។ ក្នុងការគាំទ្រដល់បណ្តឹងឧទ្ធរណ៍របស់ខ្លួន សហព្រះរាជអាជ្ញាទាញសំអាងហេតុថា ការឃុំខ្លួនបណ្តោះអាសន្នមិនមែនជាវិធានការដាក់ទណ្ឌកម្មនោះទេ[៥៧]។ ការដែលជនត្រូវចោទស្ថិតនៅក្នុងមន្ទីរឃុំឃាំង ដោយអនុលោមតាមដីកាសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន គឺមិនមែនដកហូតសិទ្ធិរបស់គាត់ក្នុងការត្រៀមរៀបចំកិច្ចការពារខ្លួននោះទេ។ ក្នុងរឿងក្តីដែលស្មុគស្មាញ ការត្រៀមរៀបចំកិច្ចការពារខ្លួនអាចគ្របដណ្តប់ជាចាំបាច់ទៅលើសកម្មភាពជាច្រើន។ វិធានការដែលជួយសម្រួលដល់ការត្រៀមរៀបចំកិច្ចការពារខ្លួន ដូចជា ការបង្កលក្ខណៈឱ្យមានការប្រាស្រ័យទាក់ទងគ្នារវាងមេធាវីការពារក្តី និងជនត្រូវចោទ មិនអាចត្រូវបានហាមឃាត់ហួសហេតុបានទេ ដោយសារថា ជនត្រូវចោទកំពុងស្ថិតនៅក្នុងមន្ទីរ

---

[៥៥] រឿងក្តីរវាង *Galystan តទល់នឹង ប្រទេសអាមេនី* បណ្តឹងឧទ្ធរណ៍លេខ ២៦៩៨៦/០៣ នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលដីកា" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ៨៤។

[៥៦] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ត្រង់ទំព័រទី ១០ (បន្ទាត់ទី ៤ ដល់ ១០)។

[៥៧] ចម្លើយតប កថាខណ្ឌ ១ ។

ឃុំឃាំង។

៣៤. ទីពីរ អង្គបុរេជំនុំជម្រះបានពិចារណាថា ១) ទំហំ និងភាពស្មុគស្មាញនៃរឿងក្តី ២) តម្រូវការការបកប្រែជាសំណេរ និងផ្ទាល់មាត់របស់ក្រុមមេធាវីការពារក្តី និងការលំបាកនៃការកត់ត្រាពាក្យសម្តី ឬក៏ការកត់ត្រាលំអិតនៃការជួបគ្នារវាងជនត្រូវចោទ និងក្រុមមេធាវីការពារក្តីរបស់ខ្លួន និង ៣) ការដែលដើមបណ្តឹងឧទ្ធរណ៍ផ្តល់ការណែនាំដល់សហមេធាវីអន្តរជាតិរបស់ខ្លួនដែលកំពុងស្ថិតនៅឯបរទេស កាន់តែផ្តល់បរិការណ៍ជុំវិញកាលៈទេសៈទាំងឡាយរបស់ក្រុមមេធាវីការពារក្តី[៥៨] ថែមទៀត។ នៅក្នុងបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីលើកឡើងថា ការផ្លាស់ប្តូរព័ត៌មានរវាងសហមេធាវីគឺជាការចាំបាច់ ដូច្នេះទើបពួកគាត់អាចបន្តបំពេញការងារជាក្រុម និង "រួមគ្នា...ធ្វើផែនការសម្រាប់ពេលខាងមុខបាន"[៥៩]។

៣៥. ដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងថា ការថតជំនួបប្រជុំជាមួយកូនក្តី គឺជាការចាំបាច់សម្រាប់ការត្រៀបរៀបចំសវនាការ និងការប្រាស្រ័យទាក់ទងជាមួយមេធាវីការពារក្តី។ អង្គបុរេជំនុំជម្រះជឿជាក់ថា ប្រសិនបើការថតនេះជាការចាំបាច់ នោះវាគឺជាមធ្យោបាយដែលស្ថិតនៅក្រោមមាត្រា ១៤(៣)(ខ) នៃ ICCPR។ មេធាវីការពារក្តីបានបង្ហាញឱ្យអង្គបុរេជំនុំជម្រះមានការជឿជាក់ថា ការនេះគឺជាការចាំបាច់សម្រាប់ការប្រាស្រ័យទាក់ទងគ្នា ដោយប្រសិទ្ធភាពជាមួយមេធាវីការពារក្តី

---

៥៨ គណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុបបានពិចារណាថា "សិទ្ធិទាំងឡាយដែលត្រូវបានធានាដោយមាត្រា ៦(៣) គឺជាសិទ្ធិទូទៅរបស់ជនជាប់ចោទ និងមេធាវីការពារក្តី។ ដើម្បីកំណត់ថា សិទ្ធិទាំងនេះត្រូវបានគោរពឬអត់នោះ វាមិនគ្រប់គ្រាន់ទេចំពោះការពិចារណាជនជាប់ចោទត្រូវបានគេដាក់ឲ្យស្ថិតនៅកន្លែងណានោះ។ ការពិចារណាក៏ត្រូវធ្វើឡើងចំពោះផងដែរចំពោះស្ថានភាពដែលក្រុមមេធាវីការពារក្តីទាំងមូលស្ថិតនៅ។ រឿងក្តីរវាង *Kurup តទល់នឹង Denmark,* ពាក្យបណ្តឹងលេខ 11219/84, របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៨៥ ត្រង់កថាខណ្ឌ ២៩១។ សូមមើលផងដែរ Pieter van Dijk និងអ្នកផ្សេងទៀត, *ទ្រឹស្តី និងការអនុវត្តជាក់ស្តែងរបស់កតិកាសញ្ញាសិទ្ធិមនុស្សអឺរ៉ុប* ដែលបានបោះពុម្ពផ្សាយលើកទី៤ (Intersentia, 2006) ត្រង់កថាខណ្ឌ ៦៣៤ (ដោយលើកឡើងថា នៅក្រោមមាត្រា ៦(៣)(ខ) "មិនមែនតែសិទ្ធិរបស់ជនជាប់ចោទនោះទេដែលត្រូវបានគេព្រួយបារម្ភ ប៉ុន្តែ សិទ្ធិរបស់មេធាវីការពារក្តីក៏ត្រូវបានគេព្រួយបារម្ភដូចគ្នាដែរ។ ដូច្នេះ ទាំងទីកន្លែងរបស់ជនជាប់ចោទ និងទាំងទីកន្លែងរបស់មេធាវីការពារក្តីត្រូវយកមកពិចារណាសម្រាប់ការវាយតម្លៃអំពីស្ថានភាពទូទៅ"។

៥៩ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៣ ។

និងការត្រៀមរៀបចំសវនាការ។ យោងតាមអ្វីដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ការប្រើប្រាស់ឧបករណ៍ថតសំឡេង/រូបភាពវីដេអូ គឺជាមធ្យោបាយមួយសម្រាប់គោលបំណងត្រៀមរៀបចំការការពារក្ដី។ ដូចគ្នានេះផងដែរ ការប្រើប្រាស់ឧបករណ៍ថតសំឡេង/រូបភាពវីដេអូ តាមរបៀបដូចដែលបានបញ្ជាក់ក្នុងសំណើសុំ គឺជាមធ្យោបាយសម្រាប់ការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទ និងមេធាវីការពារក្ដី។ ការវាយតម្លៃអំពីកាលៈទេសៈនៃករណីពិសេសនេះបង្ហាញឱ្យឃើញថា ការអនុញ្ញាតឱ្យមានការថតបែបនេះនឹងធានាថា ជនត្រូវចោទទទួលបានការត្រៀមលក្ខណៈគ្រប់គ្រាន់តាមតម្រូវការរបស់ខ្លួន។ មានតែការផ្ដល់ឱ្យមានការត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ការរៀបចំសវនាការ និងមធ្យោបាយប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនេះទេ ទើបសាលាក្ដីនេះអាចធានាបានថា សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់ជនត្រូវចោទ ត្រូវបានគោរពយ៉ាងពេញលេញ។

៣៦. លើសពីការដែលគ្រាន់តែពិចារណាទៅលើកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់ជនត្រូវចោទ ដោយអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតបានកម្រិតការវិភាគរបស់ខ្លួន ១) ដោយការសន្និដ្ឋានថា ច្បាប់ដែលនៅជាធរមានមិនមានការអនុញ្ញាតឱ្យបានច្បាស់លាស់ ឬមិនច្បាស់លាស់ ចំពោះឧបករណ៍ថតសំឡេង/រូបភាពវីដេអូ និង ២) ដោយការសន្និដ្ឋានថា សិទ្ធិរបស់ជនត្រូវចោទត្រូវបានគោរពយ៉ាងពេញលេញ តាមរយៈធនធាន ការត្រៀមលក្ខណៈ និងជំនួយដែលកំពុងមានស្រាប់រួចទៅហើយ។

៣៧. សហចៅក្រមស៊ើបអង្កេត មានកំហុសក្នុងការពិចារណាអំពីសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់ជនត្រូវចោទ។ ដោយសារខ្លួនមិនបានពិចារណាអំពីសិទ្ធិទាំងនេះ ក្រោយមកទៀតសហចៅក្រមស៊ើបអង្កេតក៏មិនបានពិចារណាថា តើតម្រូវឱ្យមានវិធានការចាប់បង្ខំ និងការអនុវត្តវិធានការបែបនេះ ទាក់ទងទៅនឹងសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ជនត្រូវចោទ ដោយអនុលោមតាមវិធាន ២១(២) នៃវិធានផ្ទៃក្នុង ដែរឬយ៉ាងណានោះ។ អង្គបុរេជំនុំជម្រះបានពិចារណាពីមុនរួចមកហើយអំពីសេចក្ដីត្រូវការអនុញ្ញាតឱ្យជនជាប់ឃុំឃាំងទាំងអស់អនុវត្តសិទ្ធិរបស់ពួកគាត់ ដែលមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង នៅក្នុងបរិបទមួយជាក់លាក់ក្នុងការគ្រប់គ្រងមន្ទីរ

ឃុំឃាំងឲ្យបានត្រឹមត្រូវ និងបញ្ញត្តិនៃវិធាន ២១(២) នៃវិធានផ្ទៃក្នុង[៦០]។ នៅក្នុងបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងជំនួបរវាងជនត្រូវចោទ និងប្រពន្ធរបស់គាត់ ដែលជាជនត្រូវចោទកំពុងស្ថិតក្នុងមន្ទីរឃាំងដែរនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតត្រូវបានកម្រិតដោយវិធាន ២១(២) នៃវិធានផ្ទៃក្នុង[៦១]។ វិធានការទាំងឡាយដែលត្រូវបានអនុវត្តជាការហាមឃាត់ទៅលើសិទ្ធិរបស់ជនត្រូវចោទ ដូចមានចែងក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង "ត្រូវកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែដំណើរការនីតិវិធីប៉ុណ្ណោះ"[៦២]។

៣៨. បន្ថែមទៅលើយុត្តាធិការផ្ទាល់របស់ខ្លួន អង្គបុរេជំនុំជម្រះបានពិចារណាទៅលើការបកស្រាយសិទ្ធិបែបនេះដោយគណៈកម្មាធិការសិទ្ធិមនុស្ស និងតុលាការសិទ្ធិមនុស្សអឺរ៉ុប។ សេចក្តីផ្តល់យោបល់ទូទៅលេខ៣២ ទៅលើមាត្រា ១៤(៣)(ខ) នៃ ICCPR ដូចដែលបានប្រកាសឲ្យប្រើដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានផ្តល់ការណែនាំចំពោះព្រំដែនកំណត់នៃការធានានូវសិទ្ធិទទួលបានមេធាវីការពារក្តី។ សេចក្តីផ្តល់យោបល់ទូទៅលេខ៣២ ចែងថា ក្នុងករណីជាប់ចោទពីបទព្រហ្មទណ្ឌ មេធាវីការពារក្តីត្រូវត្រូវមានលទ្ធភាពបំពេញកិច្ចការក្នុងនាមឲ្យកូនក្តីរបស់ខ្លួន "ដោយមិនមានការហាមឃាត់ ការជះឥទ្ធិពល ការគាបសង្កត់ ឬការជ្រៀតជ្រែកពីភាគីណាមួយឡើយ"[៦៣]។ យោងតាម ECHR ការដាក់កំហិតទៅលើសិទ្ធិប្រាស្រ័យទាក់ទងជាមួយមេធាវីការពារក្តីមិនអនុញ្ញាតឲ្យធ្វើទៅបាន ដោយមិនចាំបាច់មានយុត្តិកម្មអ្វីឡើយ[៦៤]។ សិទ្ធិរបស់

---

[៦០] សេចក្តីសម្រេចទៅលើភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ អំពីសិទ្ធិចូលជួប កថាខណ្ឌ១៥ និង ១៧ ។

[៦១] សេចក្តីសម្រេចទៅលើភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ អំពីសិទ្ធិចូលជួប កថាខណ្ឌ១៥។

[៦២] សេចក្តីសម្រេចទៅលើភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ អំពីសិទ្ធិចូលជួប កថាខណ្ឌ១៥ ។

[៦៣] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ *សេចក្តីផ្តល់យោបល់ទូទៅលេខ៣២៖ សិទ្ធិទទួលបានភាពស្មើគ្នាទៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌* ឯកសារ អ.ស.ប CCPR/C/GC/32 ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧។ សេចក្តីផ្តល់យោបល់ទូទៅលេខ៣២ ទៅលើមាត្រា១៤ គឺជំនួសឲ្យសេចក្តីផ្តល់យោបល់ទូទៅលេខ១៣ របស់គណៈកម្មាធិការសិទ្ធិមនុស្ស។

[៦៤] រឿងក្តីរវាង Kurup តទល់នឹង ប្រទេសដាណឺម៉ាក គណៈកម្មាធិការសិទ្ធិមនុស្សយល់ឃើញថា ដើម្បីជាផលប្រយោជន៍នៃការការពារសុវត្ថិភាពសាក្សី និងសុច្ចរិតភាពនៃចម្លើយរបស់សាក្សី និងអនុលោមតាមច្បាប់របស់ប្រទេសដាណឺម៉ាក ដែលអនុញ្ញាតឲ្យប្រធានតុលាការចេញដីកាសម្រេចថា ជនជាប់ចោទអាចចាកចេញពីបន្ទប់សវនាការ នៅក្នុងកាលៈទេសៈពិសេសទាំងឡាយ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង*

ជនត្រូវចោទបែបនេះ ត្រូវតែទទួលបានការគោរពឱ្យបានពេញលេញ នៅក្នុងដំណាក់កាលដែលជនត្រូវចោទកំពុងស្ថិតនៅក្នុងការឃុំខ្លួន មុនការជំនុំជម្រះក្ដី[៦៥]។

៣៩. ១) ក្រោយពីបានសួរប្រធានមន្ទីរឃុំឃាំងចំពោះយុត្តិកម្មសម្រាប់ការគ្រប់គ្រង និងការអនុវត្តដែលបង្កើតបានជាផ្នែកនៃការជូនដំណឹង និងការគ្រប់គ្រងការទទួលយកសម្ភារៈចូលទៅក្នុងមន្ទីរឃុំឃាំង និង ២) ដោយមិនបានទទួលព័ត៌មានពីប្រធានមន្ទីរឃុំឃាំង ឬពីភាគីណាមួយ ដែលបង្ហាញបញ្ជាក់ពីការព្រួយបារម្ភផ្នែកសន្ដិសុខ[៦៦] ហានិភ័យណាមួយចំពោះបុគ្គលណាម្នាក់ ឬហានិភ័យផ្សេងទៀតចំពោះសុច្ចរិតភាពនៃដំណើរការនីតិវិធី ដែលអាចធ្វើយុត្តិកម្មចំពោះការដាក់កំហិតទៅ

---

សិទ្ធិរបស់ជនជាប់ចោទក្នុងការត្រៀមរៀបចំការពារខ្លួនមិនត្រូវបានរំលោភឡើយ នៅពេលដែលជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យចាកចេញពីបន្ទប់សវនាការ ហើយមេធាវីការពារក្ដីរបស់ខ្លួនមិនត្រូវបានអនុញ្ញាតឱ្យបង្ហាញអត្តសញ្ញាណរបស់សាក្សីឱ្យកូនក្ដីរបស់ខ្លួនដឹងឡើយ។ រឿងក្ដីរវាង *Kurup តទល់នឹង ប្រទេសដាណឺម៉ាក* ពាក្យបណ្ដឹងលេខ ១១២១៩/៨៤ របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៨៥ ត្រង់ទំព័រ២៨២។ តុលាការក្នុងរឿងក្ដី *Kurup* បានកត់សម្គាល់បន្ថែមទៀតថា "វាជាការពិតហើយដែលថា លទ្ធភាពរបស់ជនជាប់ចោទក្នុងការជួបជាមួយមេធាវីការពារក្ដីរបស់ខ្លួនគឺជាផ្នែកមួយដ៏សំខាន់នៃការត្រៀមរៀបចំការពារខ្លួន។ ប៉ុន្តែ គេមិនអាចអះអាងថា សិទ្ធិជួប និងពិគ្រោះយោបល់ជាមួយមេធាវីការពារក្ដីនេះមិនអាចជាកម្មវត្ថុនៃការហាមឃាត់ណាមួយនោះទេ"។ រឿងក្ដីរវាង Kurup តទល់នឹង ប្រទេសដាណឺម៉ាក ពាក្យបណ្ដឹងលេខ ១១២១៩/៨៤ របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៨៥ ត្រង់ទំព័រ២៨១ ដល់ ២៨២។

[៦៥] អ្នកធ្វើអត្ថាធិប្បាយម្នាក់បានលើកឡើងថា "បញ្ហាសំខាន់បំផុតនៅក្រោមមាត្រា ៦(៣)(ខ) គឺសិទ្ធិប្រាស្រ័យទាក់ទងជាមួយមេធាវីក្ដី។ ចំនុចនេះមានសារៈសំខាន់បំផុតអ្នកដែលស្ថិតក្នុងមន្ទីរឃុំឃាំងកំពុងរង់ចាំសវនាការ...។ ការហាមឃាត់សិទ្ធិចូលជួបរបស់មេធាវីការពារក្ដីត្រូវតែផ្ដល់យុត្តិកម្ម ដែលជាប្រយោជន៍សាធារណៈ ដូចជា ការរារាំងមិនឱ្យមានការរត់គេចខ្លួន ឬការរារាំងមិនឱ្យមានការបង្កឧបសគ្គដល់ដំណើរការយុត្តិធម៌។ គេអាចអនុញ្ញាតឱ្យហាមឃាត់មេធាវីមិនឱ្យពិភាក្សាជាមួយកូនក្ដីរបស់ខ្លួននូវព័ត៌មានអំពីករណីដែលអាចបង្ហាញឈ្មោះអ្នកដែលផ្ដល់ព័ត៌មាន"។ Richard Clayton និង Hugh Tomlinson *សិទ្ធិទទួលការជំនុំជម្រះក្ដីដោយយុត្តិធម៌* បោះពុម្ពដោយសាកលវិទ្យាល័យ Oxford ឆ្នាំ២០០១ ទំព័រ ១១៧។

[៦៦] គណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុបបានកត់សម្គាល់ថា ការមិនមានលទ្ធភាពទទួលបានភាពសម្ងាត់ចេញពីការពិគ្រោះយោបល់អំពីសវនាការជាមួយមេធាវីការពារក្ដី អាចបង្កបានជាការបដិសេធសិទ្ធិទទួលបាននូវការជំនុំជម្រះក្ដី ដែលមានចែងក្នុងមាត្រា ៦(១) នៃ ECHR។ រឿងក្ដីរវាង *Campbell និង Fell តទល់នឹង ចក្រភពអង់គ្លេស* ពាក្យបណ្ដឹងលេខ ៧៨១៩/៧៧ និងលេខ ៧៨៧៨/៧៧ សាលក្រម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៨៤ កថាខណ្ឌ១១១។ ប៉ុន្តែ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា "អាចមានការពិចារណាទៅលើបញ្ហាសន្ដិសុខ ដែលអាចធ្វើយុត្តិកម្មចំពោះការដាក់កំហិតខ្លះទៅលើលក្ខខណ្ឌសម្រាប់មេធាវីចូលជួបអ្នកទោស"។ រឿងក្ដីរវាង *Campbell និង Fell តទល់នឹង ចក្រភពអង់គ្លេស* ពាក្យបណ្ដឹងលេខ ៧៨១៩/៧៧ និងលេខ ៧៨៧៨/៧៧ សាលក្រម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៨៤ កថាខណ្ឌ១១៣។

*សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្ដីពីការបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង*

PRE-TRIAL CHAMBER ECCC

លើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ដើមបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយការខកខានមិនបានពិចារណាថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ដើមបណ្តឹងឧទ្ធរណ៍ ដែលត្រូវបានការពារដោយវិធាន២១ នៃវិធានផ្ទៃក្នុងនោះ បានប៉ះពាល់យ៉ាងខ្លាំង ដោយសារការបដិសេធមិនអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តីរបស់ជនត្រូវចោទ យកសម្ភារៈថតសំឡេង/រូបភាពវីដេអូ ចូលក្នុងមន្ទីរឃុំឃាំង។ កំហុសអង្គច្បាប់នេះធ្វើឱ្យដីការងការជំទាស់គ្មានសុពលភាព។

៤០. បន្ទាប់ពីបានពិចារណាថា ដីកាដែលរងការជំទាស់នេះរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ អង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនបាច់អ្វីដែលត្រូវពិចារណាទៅលើមូលហេតុផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍នោះទេ។

៤១. ទោះបីជាអង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាដែលរងការជំទាស់នេះបានដកហូតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ដើមបណ្តឹងឧទ្ធរណ៍ និងគ្មានសុពលភាពក៏ដោយ ក៏អង្គបុរេជំនុំជម្រះត្រូវយកចិត្តទុកដាក់ពិចារណាមិនឱ្យមានការបំពានលើការប្រើប្រាស់សិទ្ធិ នាំយកឧបករណ៍ថតសំឡេង/រូបភាពវីដេអូ និងសម្ភារៈប្រើប្រាស់ទាំងអស់ ដែលត្រូវបានយកចូលក្នុងមន្ទីរឃុំឃាំងនោះដែរ។ ដោយការពិចារណាប្រកបដោយហេតុផលទៅលើវិធាន និងនីតិវិធីរបស់មន្ទីរឃុំឃាំង និងគោលបំណងរបស់ដើមបណ្តឹងឧទ្ធរណ៍ចំពោះការថតសំឡេង/រូបភាពវីដេអូ ដូចដែលបានបញ្ជាក់រួចមកហើយនេះ ការហាមឃាត់ដូចខាងក្រោមនេះត្រូវតែយកមកអនុវត្ត៖

១. សហមេធាវីការពារក្តីរបស់ដើមបណ្តឹងឧទ្ធរណ៍ និងសមាជិកផ្សេងទៀតនៃក្រុមការពារក្តីរបស់ជនត្រូវចោទ រួមទាំង អ្នកបកប្រែសំណេរ និងអ្នកបកប្រែផ្ទាល់មាត់តាមការចាំបាច់ ("បុគ្គលដែលត្រូវបានអនុញ្ញាត") អាចយកឧបករណ៍ ថតសំឡេង/រូបភាពវីដេអូចូលក្នុងមន្ទីរឃុំឃាំងបាន។ ឧបករណ៍ទាំងអស់ត្រូវស្ថិតនៅក្រោមនីតិវិធីត្រួតពិនិត្យ ព្រមទាំងបែបបទដែលមានស្រាប់ សម្រាប់ការចេញចូលរបស់បុគ្គលទាំងឡាយ និងសម្ភារៈផ្សេងៗ ដូចដែលបានបង្កើតឡើងដោយប្រធានមន្ទីរឃុំឃាំង។ ការថតនេះអាចធ្វើឡើងតែនៅក្នុងបន្ទប់សម្ភាសន៍នៃមន្ទីរឃុំឃាំង ដែលបានកំណត់រួចហើយ ឬកន្លែងដែលត្រូវកំណត់ដោយប្រធានមន្ទីរឃុំឃាំង។

២. ការថតដែលធ្វើឡើងដោយបុគ្គលដែលត្រូវបានអនុញ្ញាត អាចយកទៅប្រើប្រាស់សម្រាប់តែគោលបំណង នៃការត្រៀមរៀបចំកិច្ចការពារក្តីជនត្រូវចោទ និងការប្រាស្រ័យទាក់ទងគ្នាជាមួយមេធាវីការពារក្តីតែប៉ុណ្ណោះ។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ដើមបណ្តឹងឧទ្ធរណ៍ ឬបុគ្គលដែលត្រូវបានអនុញ្ញាត មិនអាចយកការថតណាមួយទៅផ្សព្វផ្សាយជាសាធារណៈ បោះពុម្ពផ្សាយក្នុងទម្រង់ណាមួយ ឬ ផ្តល់ឱ្យ ឬពិនិត្យមើលដោយជនណាម្នាក់ ឬអង្គការណាមួយ ក្រៅពីបុគ្គលដែលត្រូវបានអនុញ្ញាត និងដើមបណ្តឹងឧទ្ធរណ៍ ដោយមិនមានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក នោះឡើយ។

៣. ដោយការអនុវត្តសិទ្ធិប្រើប្រាស់ឧបករណ៍ថតសំឡេង/រូបភាពវីដេអូ នៅក្នុងមន្ទីរឃុំឃាំង ស្របតាមសេចក្តីសម្រេច ឬដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ បុគ្គលដែលត្រូវបានអនុញ្ញាតទទួលស្គាល់ និងយល់ព្រមថា រាល់ការថតទាំងអស់គឺជា "ឯកសារ" ដូចពាក្យដែលបានកំណត់ន័យ នៅក្នុងសេចក្តីណែនាំអនុវត្តលេខ០០៤/២០០៩ ស្តីពីចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងរឿងក្តី ("សេចក្តីណែនាំអនុវត្ត")។ ការថតទាំងអស់ត្រូវចាត់ចំណាត់ប្រភេទថា "ជាសម្ងាត់" ដូចដែលបានកំណត់ន័យនៅក្នុងសេចក្តីណែនាំអនុវត្ត និងបើពុំនោះទេ ត្រូវចាត់ទុកថាជា "ព័ត៌មានសម្ងាត់" ដូចពាក្យដែលបានប្រើក្នុងសេចក្តីណែនាំអនុវត្ត។ បុគ្គលដែលត្រូវបានអនុញ្ញាតទទួលស្គាល់ និងយល់ព្រមថា ប្បញ្ញត្តិទាំងអស់នៃសេចក្តីណែនាំអនុវត្ត រួមទាំង តែមិនកម្រិតត្រឹមតែមាត្រា៨ នោះទេ ត្រូវអនុវត្តចំពោះបុគ្គលដែលត្រូវបានអនុញ្ញាត និងការថតសំឡេង/រូបភាពវីដេអូទាំងអស់ នៃជំនួបជាមួយជនត្រូវចោទនៅក្នុងមន្ទីរឃុំឃាំង។ ការខកខានមិនគោរពតាមការហាមឃាត់ស្តីពីការថតសំឡេង/រូបភាពវីដេអូ ដូចបានកំណត់ក្នុងសេចក្តីសម្រេច ឬដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ នោះបុគ្គលដែលត្រូវបានរកឃើញថាបានប្រព្រឹត្តការរំលោភបែបនេះ ត្រូវទទួលការដាក់ទណ្ឌកម្មដោយអង្គបុរេជំនុំជម្រះ ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ ការខកខានមិនគោរពតាមការហាមឃាត់ស្តីពីការថតសំឡេង/រូបភាពវីដេអូ ដែលជា "ឯកសារសម្ងាត់" និង/ឬ "ព័ត៌មានសម្ងាត់" ត្រូវចាត់ទុកថា ជាការរំលោភលើសេចក្តីណែនាំអនុវត្ត។ បុគ្គល



E.C.C.C * C.E.T.C
CHAMBER CHAMBRE PRELIMINAIRE

ទាំងឡាយណារំលោភសេចក្តីសម្រេច និងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ ត្រូវទទួលការដាក់ទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា ១១ នៃសេចក្តីណែនាំអនុវត្ត។

៤២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា បើទោះបីជាជនត្រូវចោទទាំងអស់មិនបានធ្វើ ឬមិនបានចូលរួមនៅក្នុងសំណើសុំនេះក៏ដោយ ដោយយោងទៅលើការពិតដែលថា សិទ្ធិដែលបានបញ្ជាក់នៅក្នុងសាលដីកានេះ គឺជាសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ នោះសិទ្ធិដែលបានលើកឡើងនៅក្នុងសាលដីកានេះ ត្រូវបន្តផ្តល់ឱ្យក្រុមមេធាវីការពារក្តីរបស់ជនត្រូវចោទដទៃទៀត ដែលកំពុងជាប់នៅក្នុងមន្ទីរឃុំឃាំង ដោយអនុលោមតាមលក្ខខណ្ឌ ដែលមាននៅក្នុងកថាខណ្ឌខាងលើនេះ និងការសម្រេចដូចខាងក្រោមនេះ។

៤៣. ដើមបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញា និងប្រធានមន្ទីរឃុំឃាំងមានសិទ្ធិសេរីភាពក្នុងការដាក់សំណើសុំមកអង្គបុរេជំនុំជម្រះដើម្បីស្នើសុំការណែនាំបន្ថែមទៀត ទាក់ទងនឹងការអនុវត្តសាលដីកានេះ ប្រសិនបើមានតម្រូវការ។

## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា ៖

១. បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

២. ច្រានចោលដីកាដែលរងការជំទាស់។

៣. បង្គាប់ឱ្យប្រធានមន្ទីរឃុំឃាំងអនុញ្ញាតឱ្យបុគ្គល ដែលត្រូវបានអនុញ្ញាត យកឧបករណ៍ថតសំឡេង/រូបភាពវីដេអូ ចូលក្នុងមន្ទីរឃុំឃាំង ដោយអនុលោមតាមសាលដីកានេះ និងស្របតាមបែបបទទាក់ទងនឹងការត្រួតពិនិត្យ និងការប្រើប្រាស់ឧបករណ៍បែបនេះ ដែលអាចត្រូវបានអនុវត្តដោយបុគ្គលិកនៃមន្ទីរឃុំឃាំង តាមការណែនាំរបស់ប្រធាន។

៤. សិទ្ធិប្រើប្រាស់ឧបករណ៍ថតសំឡេង/រូបភាពវីដេអូ ដើម្បីថតការជួបជាមួយកូនក្តី នៅក្នុងមន្ទីរឃុំឃាំងគឺត្រូវតែធ្វើទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកថាខណ្ឌ៤១ ក្នុងសាលដីកានេះ។

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦៤)

លេខ/No. A371/2/12

ដើម្បីជម្រះឲ្យអស់មន្ទិលសង្ស័យ លក្ខខណ្ឌក្នុងកថាខណ្ឌ៤១ ត្រូវបានបញ្ចូលជាឯកសារយោងនៅក្នុងដីកានេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **ន័យ ថុល** **Catherine MARCHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**